ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០០៣៩ ពណ. ៥០៧

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង

យោងប្រកាសលេខ២៩៩ ពណ.ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងពាណិជ្ជកម្មស្តីពីនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម បានកំណត់ឲ្យចុះបញ្ជីពាណិជ្ជកម្មនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ: www.businessregistration.moc.gov.kh ហើយការបង់កម្រៃសេវាចូលជាថវិការដ្ឋអាចធ្វើបានតាមប្រព័ន្ធ អេឡិចត្រូនិចរបស់ធនាគារពាណិជ្ជ។

ការបង់កម្រៃសេវាតាមរយៈប្រព័ន្ធអេឡិកត្រូនិករបស់ធនាគារពាណិជ្ជនាពេលបច្ចុប្បន្ន ទើបតែមានធនាគារ ACLEDA មួយប៉ុណ្ណោះ ដែលបានភ្ជាប់ប្រព័ន្ធទូទាត់ជាមួយនឹងប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។ តាំងពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦មក ប្រព័ន្ធទូទាត់របស់ធនាគារ ACLEDA មានបញ្ហាអាក់អួលផ្នែកបច្ចេកទេស បណ្តាលឲ្យការ ទូទាត់ប្រាក់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម (electronic Payment) មិនអាចធ្វើបានដោយរលូន។

ទោះបីជាការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកមានភាពអាក់អួលក៏ដោយ តែអតិថិជនទាំងអស់នៅតែអាចធ្វើការទូទាត់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មនៅធនាគារ ACLEDA, ធនាគារ CANADIA និង ធនាគារ FOREIGN TRADE BANK តាមគ្រប់មធ្យោបាយទូទាត់ដែលផ្តល់ដោយធនាគារ ដូចជា បង់ប្រាក់ដោយផ្ទាល់នៅតាមសាខារបស់ធនាគារ ការទូទាត់ដែលប្រើសេវា Credit/Debit Cards, Internet Banking, Mobile Banking ឬផ្ទេរប្រាក់ពីគណនីធនាគាររបស់អស់លោកអ្នក ចូលមកគណនីរបស់ក្រសួងពាណិជ្ជកម្មនៅធនាគារទាំងបី ដូចខាងក្រោម៖

១. ធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB)
   KHR: 010-01-290-000094-0
   USD: 010-30-063-000937-8

២. ធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA)
   KHR: 0001-02-076702-27
   USD: 0001-02-076702-18

៣. ធនាគារកាណាឌីយ៉ា ក.អ (CANADIA)
   KHR: 001-000-333-88-22
   USD: 001-000-333-55-88

ក្រសួងពាណិជ្ជកម្មកំពុងសហការជាមួយធនាគារពាណិជ្ជដើម្បីដាក់ឲ្យដំណើរការឡើងវិញនូវការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ហើយក្រសួងនឹងជូនដំណឹងជាថ្មីម្តងទៀតនៅពេលឆាប់ៗខាងមុខ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងនៅឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី នៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងតាមទូរស័ព្ទលេខ ០២៣ ៨៦៦ ០៥០។